# សម្រាប់អ្នកដែលមានប័ណ្ណបើកបររបស់បរទេស

## វិធីបើកបរនៅក្នុងប្រទេសជប៉ុន

■ ដើម្បីអាចបើកបរនៅក្នុងប្រទេសជប៉ុន លោកអ្នកត្រូវមានប័ណ្ណបើកបរណាមួយដូចខាងក្រោមនេះ។

1) ប័ណ្ណបើកបរជប៉ុន

2) ប័ណ្ណបើកបរអន្តរជាតិដែលអនុលោមតាមអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក (អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩)

＊ លោកអ្នកមិនអាចបើកបរដោយប្រើប័ណ្ណបើកបរអន្តរជាតិបានទេ ក្នុងករណីប័ណ្ណនោះមិនបានចេញដោយប្រទេសជាសមាជិកនៃអនុសញ្ញាទីក្រុងហ្សឺណែវឬក្នុងករណីដែលប្រទេសនោះជាសមាជិក មែន ក៏ប៉ុន្តែមិនបានចេញប័ណ្ណតាមទម្រង់នៃអនុសញ្ញាទីក្រុងហ្សឺណែវ។

3) ប័ណ្ណបើកបររបស់បរទេស

ចំពោះប័ណ្ណបើកបរដែលចេញដោយប្រទេសឬតំបន់ដែលមិនបានចេញប័ណ្ណបើកបរអន្តរជាតិ ប៉ុន្តែត្រូវបានទទួលស្គាល់ថា មានប្រព័ន្ធអាជ្ញាប័ណ្ណកម្រិតស្មើនឹងប្រទេសជប៉ុន(គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦៖ សហព័ន្ធស្វីស សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សាធារណរដ្ឋបារាំង ព្រះរាជាណាចក្របែលហ្ស៊ិក អាណាចក្រម៉ូណាកូ និងតៃវ៉ាន់) ក្នុងករណីនេះ ប័ណ្ណបើកបរត្រូវតែមានភ្ជាប់មកជាមួយឯកសារបកប្រែជាភាសាជប៉ុនដែលរៀបចំដោយ ※ស្ថាប័នដែលកំណត់ដោយអនុក្រឹត្យ។

＊ ស្ថាប័នដែលកំណត់ដោយអនុក្រឹត្យសម្រាប់រៀបចំឯកសារបកប្រែជាភាសាជប៉ុនមានដូចខាងក្រោម។ អ្នកបកប្រែដែលច្បាប់បានកំណត់របស់បរទេសមិនត្រូវបានរាប់បញ្ចូលឡើយ។

○ អាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅជាដើមដែលមានសមត្ថកិច្ចចេញប័ណ្ណបើកបរ ឬស្ថាប័នកុងស៊ុលនៃប្រទេសនោះ (ស្ថាប័នចេញប័ណ្ណបើកបរ ឬស្ថានទូត/ស្ថានកុងស៊ុលនៃប្រទេសនោះប្រចាំប្រទេសជប៉ុន)។

○ អាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅជាដើមដែលគ្រប់គ្រងច្បាប់ដែលមានតម្លៃស្មើនឹងច្បាប់ចរាចរណ៍ផ្លូវគោក (កំណត់ត្រឹមផ្នែកពាក់ព័ន្ធនឹងប័ណ្ណបើកបរ។) គឺជានីតិបុគ្គល ឬបុគ្គលដទៃទៀតនៃប្រទេសក្រៅ ដែលបានជូនដំណឹងដល់គណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិជប៉ុនថា ជាបុគ្គលដែលមានសមត្ថភាពក្នុងការរៀបចំឯកសារបកប្រែជាភាសាជប៉ុននៃប័ណ្ណបើកបរនៃប្រទេសនោះ និងត្រូវបានគណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិទទួលស្គាល់ថាត្រឹមត្រូវ (គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ប័ណ្ណបើកបរតៃវ៉ាន់ ត្រូវបានទទួលស្គាល់ដោយ សមាគមទំនាក់ទំនងតៃវ៉ាន់-ជប៉ុន និង ប័ណ្ណបើកបរអាល្លឺម៉ង់ ត្រូវបានទទួលស្គាល់ដោយ សហព័ន្ធរថយន្តអាល្លឺម៉ង់) (គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ប័ណ្ណបើកបរតៃវ៉ាន់ ត្រូវបានទទួលស្គាល់ដោយ សមាគមទំនាក់ទំនងតៃវ៉ាន់-ជប៉ុន និង ប័ណ្ណបើកបរអាល្លឺម៉ង់ ត្រូវបានទទួលស្គាល់ដោយ សហព័ន្ធរថយន្តអាល្លឺម៉ង់) (គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ប័ណ្ណបើកបរតៃវ៉ាន់ ត្រូវបានទទួលស្គាល់ដោយ សមាគមទំនាក់ទំនងតៃវ៉ាន់-ជប៉ុន និង ប័ណ្ណបើកបរអាល្លឺម៉ង់ ត្រូវបានទទួលស្គាល់ដោយ សហព័ន្ធរថយន្តអាល្លឺម៉ង់)។

○ ននីតិបុគ្គលដែលត្រូវបានកំណត់ដោយគណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិជប៉ុនថា អាចរៀបចំឯកសារបកប្រែជាភាសាជប៉ុននៃប័ណ្ណបើកបរដែលពាក់ព័ន្ធនឹងប័ណ្ណបើកបររបស់អាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅស្តីពី ការបើកបរយានយន្តយ៉ាងត្រឹមត្រូវនិងប្រាកដ។

■ រយៈពេលដែលអាចបើកបរបាននៅក្នុងប្រទេសជប៉ុន

1) ប័ណ្ណបើកបរជប៉ុន

ក្នុងកំឡុងពេលដែលមានសុពលភាព

2) ប័ណ្ណបើកបរអន្តរជាតិនិងប័ណ្ណបើកបររបស់បរទេស

រយៈពេល១ឆ្នាំដោយគិតចាប់ពីថ្ងៃដែលបានមកដល់ប្រទេសជប៉ុនឬរយៈពេលនៃសុពលភាពនៃប័ណ្ណបើកបរនោះ *1 យកកាលបរិច្ឆេទណាមួយដែលខ្លីជាង (ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបុគ្គលដែលមានឈ្មោះក្នុងបញ្ជីស្នាក់នៅជាមូលដ្ឋានបានចាកចេញពីប្រទេសជប៉ុនដោយទទួលបានការបញ្ជាក់ការចាកចេញ ឬការអនុញ្ញាតឱ្យចូលប្រទេសវិញជាដើម ហើយបានត្រឡប់មក (មកដល់) ប្រទេសជប៉ុនវិញក្នុងរយៈពេលតិចជាង៣ខែ ថ្ងៃដែលត្រឡប់មកវិញ(មកដល់)នោះ មិនត្រូវបានរាប់ជាថ្ងៃចាប់ផ្តើមនៃ *2 រយៈពេលដែលអាចបើកបរបាន ដោយប្រើប័ណ្ណបើកបរអន្តរជាតិឡើយ។)

*1 សុពលភាពនៃប័ណ្ណបើកបរអន្តរជាតិគឺ១ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញប័ណ្ណ

*2 សូមពិនិត្យមើលផ្សាក្រោមដោយឡែក អំពីរយៈពេលដែលអាចបើកបរបានដោយប្រើប័ណ្ណបើកបរអន្តរជាតិ។

## **វិធីសម្រាប់ទទួលបានប័ណ្ណបើកបរជប៉ុន**

អ្នកដែលទទួលបានប័ណ្ណបើកបរពីអាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅជាដើម អាចដាក់ពាក្យសុំនីតិវិធីដោយទទួលបានការលើកលែងការប្រឡងមួយផ្នែក ដើម្បីទទួលបានប័ណ្ណបើកបរជប៉ុនដែលពាក់ព័ន្ធនឹងយានយន្តជាដើមដែលអាចបើកបរបានដោយប័ណ្ណបើកបរនោះ

■ ទីកន្លែងដាក់ពាក្យ

មជ្ឈមណ្ឌលផ្តល់ប័ណ្ណបើកបរនៃស្នងការដ្ឋាននគរបាលខេត្តដែលគ្រប់គ្រងលើអាសយដ្ឋានស្នាក់នៅរបស់លោកអ្នកនៅក្នុងប្រទេសជប៉ុន

■ នីតិវិធី

ដោយផ្អែកលើពាក្យសុំ នឹងធ្វើការបញ្ជាក់ចំណេះដឹងចាំបាច់ឬជំនាញពាក់ព័ន្ធនឹងការបើកបរ ហើយប្រសិនបើត្រូវបានទទួលស្គាល់ថាគ្មានឧបសគ្គដល់ការបើកបរ នោះលោកអ្នកនឹងត្រូវបានលើកលែងការប្រឡងមួយផ្នែក(ប្រឡងទ្រឹស្តី និងការប្រឡងអនុវត្ត)។

■ ការប្រុងប្រយ័ត្ន

1) លក្ខខណ្ឌស្នាក់នៅគឺ ក្រោយលោកអ្នកទទួលបានប័ណ្ណបើកបរប្រទេសក្រៅជាដើម បានស្នាក់នៅក្នុងប្រទេសនោះជាដើម សរុបរយៈពេលយ៉ាងតិច៣ខែឡើង (តម្រូវឱ្យមានឯកសារបញ្ជាក់រយៈពេលស្នាក់នៅ ដូចជាលិខិតឆ្លងដែនដែលមានត្រាចេញ-ចូលជាដើម)។

2) មិនអនុញ្ញាតឱ្យដាក់ពាក្យតាមរយៈតំណាងឡើយ។ សាមីខ្លួនត្រូវតែមកដាក់ពាក្យដោយផ្ទាល់ជាដាច់ខាត។

3) ជនបរទេសដែលមិនស្ថិតក្រោមច្បាប់បញ្ជីស្នាក់នៅជាមូលដ្ឋាន ជាគោលការណ៍ មិនអាចដាក់ពាក្យសុំប័ណ្ណបើកបរបានទេ

លើកលែងតែករណីលើកលែងដែលកំណត់ដោយច្បាប់និងបទពញ្ញា។

ករណីលើលលែងដែលអាចដាក់ពាក្យសុំប័ណ្ណបើកបរបាន

បុគ្គលដែលអាចបង្ហាញប័ណ្ណសម្គាល់ខ្លួនដែលចេញដោយក្រសួងការបរទេស (ប័ណ្ណសម្គាល់ខ្លួនអ្នកការទូតជាដើម) ឬឯកសារបញ្ជាក់អត្តសញ្ញាណដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិថាមានតម្លៃស្មើនឹងប័ណ្ណសម្គាល់ខ្លួនចេញដោយក្រសួងការបរទេស

ក្នុងករណីដែលស្ថិតក្នុងករណីលើកលែងនេះ នៅពេលដាក់ពាក្យសុំប័ណ្ណបើកបរក្រៅពីការបង្ហាញឯកសារខាងលើ លោកអ្នកត្រូវដាកឯកសារដែលចេញដោយស្ថាប័នសាធារណៈដែលគ្រប់គ្រាន់ដើម្បីបញ្ជាក់អាសយដ្ឋានស្នាក់នៅ។

សូមសាកសួរនៅមជ្ឈមណ្ឌលផ្តល់ប័ណ្ណបើកបរនៃស្នងការដ្ឋាននគរបាលខេត្តនីមួយៗ សម្រាប់ព័ត៍មានលម្អិត។

■ ឯកសារចាំបាច់ដម្រាប់ការដាក់ពាក្យសុំប័ណ្ណបើកបរ

1)ទម្រង់បែបបទដាក់ពាក្យ

＊ លោកអ្នកត្រូវដាក់«ប័ណ្ណសំណួរ»ស្តីអំពីរោគសញ្ញានៃជំងឺជាដើម ព្រមជាមួយទម្រង់បែបបទដាក់ពាក្យ។ ករណីលោកអ្នកមានចំណុចណាមួយដែលត្រូវនឹងសំណួរ មន្ត្រីនឹងសាកសួរព័ត៍មានលម្អិតស្តីអំពីរោគសញ្ញា។

2) រូបថតសម្រាប់ទម្រង់បែបបទដាក់ពាក្យ ១សន្លឹក

＊ ត្រូវជារូបថតក្នុងរយៈពេល៦ខែមុនពេលដាក់ពាក្យដែលមិនពាក់មួក (លើកលែងតែករណីគ្របក្បាលដោយក្រណាត់ដោយសារមូលហេតុសាសនាឬវេជ្ជសាស្ត្រដែលអាចមើលឃើញទម្រង់មុខច្បាស់) បែរមុខចំ គ្មានផ្ទៃខាងក្រោយ និងថតចាប់ពីទ្រូងឡើងលើ។ ទំហំ 3.0 x 2.4 សង់ទីម៉ែត្រ។ ត្រូវសរសេរពីឈ្មោះនិងកាលបរិច្ឆេទថតនៅខាងក្រោយរូបថត។

3) សេចក្តីចម្លងបញ្ជីស្នាក់នៅដែលមានបញ្ជាក់ពីស្រុកកំណើត (ចំពោះជនបរទេសគឺប្រការជាក់លាក់)

＊ ប្រការជាក់លាក់គឺសំដៅលើប្រការដែលត្រូវបានកំណត់ឱ្យបញ្ជាក់នៅក្នុងបញ្ជីស្នាក់នៅរបស់ជនបរទេស តាមច្បាប់ស្តីពីបញ្ជីស្នាក់នៅជាមូលដ្ឋាន ដូចជាលក្ខណៈសម្បត្តិស្នាក់នៅនិងរយៈពេលស្នាក់នៅជាដើម។

4) ឯកសារដែលបញ្ជាក់អត្តសញ្ញាណណាមួយ ដូចជាប័ណ្ណលេខអត្តសញ្ញាណបុគ្គល លិខិតឆ្លងដែនជាដើម

5) ប័ណ្ណបើកបររបស់បរទេស(មិនអនុញ្ញាតឱ្យប្រើប័ណ្ណបើកបរអន្តរជាតិឡើយ)

6) ឯកសារបកប្រែជាភាសាជប៉ុននៃប័ណ្ណបើកបរខាងលើ(ដែលរៀបចំដោយបុគ្គលដែលកំណត់ដោយអនុក្រឹត្យ ＊ ដូចជអាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅជាដើមដែលចេញប័ណ្ណនោះ ឬស្ថាប័នកុងស៊ុលជាដើមនៃប្រទេសនោះដែលមានការបញ្ជាក់ច្បាស់លាស់នូវព័ត៍មានចាំបាច់ ដូចជាប្រភេទយានយន្តជាដើមដែលអាចបើកបរបាន សុពលភាពប័ណ្ណបើកបរ និងលក្ខខណ្ឌនៃប័ណ្ណនោះ។

＊ ស្ថាប័នដែលកំណត់ដោយអនុក្រឹត្យសម្រាប់រៀបចំឯកសារបកប្រែជាភាសាជប៉ុនមានដូចខាងក្រោម។ អ្នកបកប្រែដែលច្បាប់បានកំណត់របស់បរទេសមិនត្រូវបានរាប់បញ្ចូលឡើយ។

○ អាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅជាដើមដែលមានសមត្ថកិច្ចចេញប័ណ្ណបើកបរ ឬស្ថាប័នកុងស៊ុលនៃប្រទេសនោះ (ស្ថាប័នចេញប័ណ្ណបើកបរ ឬស្ថានទូត/ស្ថានកុងស៊ុលនៃប្រទេសនោះប្រចាំប្រទេសជប៉ុន)។

○ អាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅជាដើមដែលគ្រប់គ្រងច្បាប់ដែលមានតម្លៃស្មើនឹងច្បាប់ចរាចរណ៍ផ្លូវគោក

(កំណត់ត្រឹមផ្នែកពាក់ព័ន្ធនឹងប័ណ្ណបើកបរ។) គឺជានីតិបុគ្គល ឬបុគ្គលដទៃទៀតនៃប្រទេសក្រៅ ដែលបានជូនដំណឹងដល់គណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិជប៉ុនថា ជាបុគ្គលដែលមានសមត្ថភាពក្នុងការរៀបចំឯកសារបកប្រែជាភាសាជប៉ុននៃប័ណ្ណបើកបរនៃប្រទេសនោះ និងត្រូវបានគណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិទទួលស្គាល់ថាត្រឹមត្រូវ (គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ប័ណ្ណបើកបរតៃវ៉ាន់ ត្រូវបានទទួលស្គាល់ដោយ សមាគមទំនាក់ទំនងតៃវ៉ាន់-ជប៉ុន និង ប័ណ្ណបើកបរអាល្លឺម៉ង់ ត្រូវបានទទួលស្គាល់ដោយ សហព័ន្ធរថយន្តអាល្លឺម៉ង់) (គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ប័ណ្ណបើកបរតៃវ៉ាន់ ត្រូវបានទទួលស្គាល់ដោយ សមាគមទំនាក់ទំនងតៃវ៉ាន់-ជប៉ុន និង ប័ណ្ណបើកបរអាល្លឺម៉ង់ ត្រូវបានទទួលស្គាល់ដោយ សហព័ន្ធរថយន្តអាល្លឺម៉ង់) (គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ប័ណ្ណបើកបរតៃវ៉ាន់ ត្រូវបានទទួលស្គាល់ដោយ សមាគមទំនាក់ទំនងតៃវ៉ាន់-ជប៉ុន និង ប័ណ្ណបើកបរអាល្លឺម៉ង់ ត្រូវបានទទួលស្គាល់ដោយ សហព័ន្ធរថយន្តអាល្លឺម៉ង់)។

- នីតិបុគ្គលដែលត្រូវបានកំណត់ដោយគណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិជប៉ុនថា អាចរៀបចំឯកសារបកប្រែជាភាសាជប៉ុននៃប័ណ្ណបើកបរដែលពាក់ព័ន្ធនឹងប័ណ្ណបើកបររបស់អាជ្ញាធររដ្ឋបាលនៃប្រទេសក្រៅស្ដីពីការបើកបរយានយន្តយ៉ាងត្រឹមត្រូវនិងប្រាកដ។

7) ឯកសារដូចជាលិខិតឆ្លងដែនដែលមានត្រាចេញ-ចូល ដើម្បីបញ្ជាក់ថាលោកអ្នកបានស្នាក់នៅក្នុងប្រទេសក្រៅនោះ សរុបរយៈពេលយ៉ាងតិច៣ខែ ក្រោយទទួលបានប័ណ្ណបើកបរនោះ

8) កម្រៃសេវា

■ ផ្សេងទៀត

ការពិគ្រោះយោបល់អំពីជំងឺឬពិការភាពជាដើម ត្រូវបានទទួលសាកសួរនៅបញ្ជរពិគ្រោះយោបល់ការបើកបរដោយសុវត្ថិភាពនៃស្នងការដ្ឋាននគរបាលខេត្តនីមួយៗ។

សូមសាកសួរដោយផ្ទាល់នៅមជ្ឈមណ្ឌលផ្ដល់ប័ណ្ណបើកបរនៃស្នងការដ្ឋាននគរបាលខេត្តដែលលោកអ្នករស់នៅសម្រាប់ព័ត៌មានលម្អិតអំពីកន្លែងដាក់ពាក្យ ម៉ោងទទួលពាក្យ ឯកសារចាំបាច់និងកម្រៃសេវា។

# វិធីបើកបរយានយន្តជាដើមនៅក្នុងប្រទេសជប៉ុន

## ករណីមិនទទួលបានប័ណ្ណបើកបរនៅក្នុងប្រទេសជប៉ុន

### 1 ការបើកបរដោយប័ណ្ណបើកបរអន្តរជាតិ



(ប័ណ្ណបើកបរអន្តរជាតិនៃអនុសញ្ញាទីក្រុងហ្សឺណែវ)

○ លោកអ្នកអាចបើកបរបានក្នុងរយៈពេល១ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលមកដល់ប្រទេសជប៉ុន ដោយការកាន់កាប់នូវប័ណ្ណបើកបរអន្តរជាតិដែលមានទម្រង់ស្របទៅតាមបទដ្ឋានដែលបានកំណត់ក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ※។(ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក មាត្រា១០៧-២)

※ អនុសញ្ញាទីក្រុងហ្សឺណែវ

អនុសញ្ញាស្តីអំពីចរាចរណ៍ផ្លូវគោកដែលត្រូវបានចុះហត្ថលេខានៅទីក្រុងហ្សឺណែវនៅថ្ងៃទី១៩ខែ៩ឆ្នាំ១៩៤៩

### 2 ការបើកបរដោយប័ណ្ណបើកបរអន្តរជាតិដោយមានភ្ជាប់ជាមួយឯកសារបកប្រែជាភាសាជប៉ុន



(ប័ណ្ណបើកបររបស់បរទេស)

\+


(ឯកសាបកប្រែជាភាសាជប៉ុន)

○ ពេលលោកអ្នកអាចបើកបរបានក្នុងរយៈពេល1ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលបានមកដល់នៅក្នុងប្រទេសជប៉ុន ដោយការកាន់កាប់※ប័ណ្ណបើកបររបស់បរទេសឬតំបន់ដែលភ្ជាប់ជាមួយ※ឯកសារបកប្រែជាភាសាជប៉ុន។ (ច្បាប់ស្តីអំពីចរាចរណ៍ផ្លូវគោក មាត្រា107-2)

※ ប័ណ្ណបើកបរនៃបរទេសឬតំបន់

ប័ណ្ណបើកបររបស់ស្វីស អាល្លឺម៉ង់ បារាំង ប៊ែលហ្ស៊ិក ម៉ូណាកូ តៃវ៉ាន់

※ ឯកសារបកប្រែជាភាសាជប៉ុនដែល

ត្រូវកំណត់ចំពោះតែឯកសារដែលត្រូវបានរៀបចំឡើងដោយស្ថាបនកុងស៊ុលនៃប្រទេសដែលបានចេញប័ណ្ណបើកបរនោះឬនីតិបុគ្គលជាដើមដែលត្រូវបានកំណត់ដោយគណៈកម្មាធិការសុវត្ថិភាពសាធារណៈជាតិប៉ុណ្ណោះ។

## ករណីទទួលបានប័ណ្ណបើកបរជប៉ុន

### 1 ការទទួលបានដោយប្រឡងប័ណ្ណបើកបរតាមនីតិវិធីធម្មតា (អ្នកដែលមិនទទួលបានប័ណ្ណបើកបររបស់បរទេស)




○ អ្នកដែលមិនទទួលបានប័ណ្ណបើកបររបស់បរទេស ត្រូវធ្វើប្រឡងប័ណ្ណបើកបរនីតិវិធីធម្មតា បន្ទាប់មកត្រូវទទួលបានប័ណ្ណបើកបរជប៉ុន។

### 2 ការទទួលបានប័ណ្ណបើកបរតាមរយៈការប្តូរពីប័ណ្ណបើកបររបស់បរទេស(អ្នកដែលទទួលបានប័ណ្ណបើកបររបស់បរទេស)



(ប័ណ្ណបើកបររបស់បរទេស)

○ អ្នកដែលត្រូវទទួលស្គាល់ថា មានចំណេះដឹងនិងជំនាញចាំបាច់សម្រាប់ការបើកបរយានយន្តជាដើម ហើយគ្មានឧបសគ្គដល់ការបើកបរគឺអាចធ្វើការប្តូរប័ណ្ណបើកបរបាន។

○ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌគឺលោកអ្នកត្រូវតែបានស្នាក់នៅក្នុងប្រទេសដែលចេញប័ណ្ណបើកបរនោះ សរុបរយៈពេលយ៉ាងតិច៣ខែបន្ទាប់ពីទទួលបានប័ណ្ណបើកបរពីប្រទេសនោះ។

រូបភាពភ្ជាប់

# រយៈពេលដែលអាចបើកបរដោយប័ណ្ណបើកបរអន្តរជាតិ(IDP)

## 1 ករណីអ្នកដែលមិនមានឈ្មោះក្នុងបញ្ជីស្នាក់នៅជាមូលដ្ឋានបានមកដល់ប្រទេសជប៉ុន

### (1) ករណីបានមកដល់ប្រទេសជប៉ុនលើកដំបូង ក្រោយទទួលបានប័ណ្ណបើកបរអន្តរជាតិ




### (2) ករណីទទួលបានប័ណ្ណបើកបរអន្តរជាតិ ក្រោយបានមកដល់ប្រទេសជប៉ុនលើកដំបូង




## 2 ករណីអ្នកដែលមានឈ្មោះក្នុងបញ្ជីស្នាក់នៅជាមូលដ្ឋានបានចាកចេញពីប្រទេសជប៉ុនហើយត្រឡប់មកដល់វិញ

### (1) ករណីត្រឡប់មកដល់ប្រទេសជប៉ុនវិញ បន្ទាប់ពីបានស្នាក់នៅបរទេសចាប់ពី៣ខែឡើងទៅ។



## (2) ករណីត្រឡប់មកដល់ប្រទេសជប៉ុនវិញ ក្នុងរយៈពេលស្នាក់នៅបរទេសតិចជាង៣ខែ (ករណីដែលមានច្រើនចំពោះជនបរទេស)




## (3) ករណីត្រឡប់មកដល់ប្រទេសជប៉ុនវិញ ក្នុងរយៈពេលស្នាក់នៅតិចជាង៣ខែ (ករណីដែលមានច្រើនចំពោះជនជាតិជប៉ុន)

